# Living the Lotus

## Buddhism in Everyday Life

9
2025
VOL. 240



Rissho Kosei-kai of Sri Lanka

Living the Lotus
Vol. 240 (September 2025)

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.



# ការរៀបចំត្រៀមខ្លួនសម្រាប់រដូវស្លឹកឈើជ្រុះនិងរដូវរងានៃជីវិត

ដោយព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ

## អ្វីដែលទៅបាត់ទៅហើយនឹងទៅបាត់ ហើយនឹងបានបំពេញមកវិញ

គេច្រើនតែប្រៀបប្រដូចជីវិតទៅនឹងរដូវទាំងបួន។ នៅពេលដែលគ្រាប់ពូជជីវិតចេញពន្លកហើយលូតលាស់ គឺជារដូវផ្ការីក ។រដូវក្ដៅគឺជាដំណាក់កាលនៃសកម្មភាពដ៏សកម្មពោរពេញដោយថាមពលនៅក្នុងសង្គម។ រដូវស្លឹកឈើជ្រុះគឺជារយៈពេលប្រមូលផល ជាពេលដែលមនុស្សយើងចាស់ទុំទៅជាមនុស្សម្នាម្នាក់ដ៏មានផ្លែផ្កា ហើយត្រៀមខ្លួនរង់ចាំរដូវរងាជាមួយនឹងពេលវេលាដែលប្រព្រឹត្តទៅមួយៗ។រដូវរងាគឺជារយៈពេលដែលយើងចំណាយពេលដោយស្ងប់ស្ងាត់បន្ទាប់ពីបានប្រមូលផលនៃជីវិត ហើយរង់ចាំពន្លកថ្មីនៃគ្រាប់ពូជដែលធ្លាក់ពីខ្លួនយើង។

មនុស្សគេបកស្រាយអ្វីទាំងនេះខុសៗគ្នា ប៉ុន្តែបើគិតតាមស្ថានភាពបច្ចុប្បន្នដែល "អាយុកាលមនុស្សមាន ១០០ ឆ្នាំ" ខ្ញុំព្រះករុណាអាត្មាភាពគិតថា និទាឃរដូវមានរយៈពេលប្រហែលជា ២៥ ឆ្នាំ រដូវក្ដៅចាប់ពីអាយុ២៦រហូតដល់អាយុ ៥០ ឆ្នាំ រដូវស្លឹកឈើជ្រុះពីអាយុ៥១រហូតដល់អាយុ ៧៥ ឆ្នាំ និងរដូវរងាចាប់ពីអាយុ៧៥ឆ្នាំឡើងទៅ។

ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមរដូវទាំងបួន រូបភាពនៃរយៈពេលពីរដូវស្លឹកឈើជ្រុះដល់រដូវរងាមិនមានភាពរស់រវើកឬសកម្មទេ ហើយខ្ញុំព្រះករុណាអាត្មាភាពគិតថាសម្រាប់មនុស្សជាច្រើន វាបង្ហាញនូវភាពរងា អារម្មណ៍ឯកោនៃស្លឹកឈើដែលក្រៀមស្រពោនហើយជ្រុះចាកមែកនិងការស៊ូទ្រាំចំពោះខ្យល់ត្រជាក់និងព្រិល។

មានកំណាព្យ haiku របស់កវីអ៊ីដា រ្យូតា( Iida Ryuta) ដែលសរសេរថា "អ្វីដែលទៅផុតទៅហើយបានទៅផុត ហើយមេឃនៃរដូវស្លឹកឈើជ្រុះក៏បានបំពេញឡើងវិញ" ។ រដូវស្លឹកឈើជ្រុះនៃជីវិតគឺជាពេលវេលាមួយដែលពួកយើងរួចខ្លួនបន្តិចម្ដងៗពីអ្វីដែលយើងធ្លាប់បានទទួលក្ដីរំខាន ហើយឆ្ពោះទៅរករដូវរងាជាមួយនឹងអារម្មណ៍ស្រស់ស្រាយ ពោរពេញដោយសេចក្ដីសង្ឃឹមនៅក្នុងចិត្ត។

ទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំព្រះករុណាអាត្មាភាពជឿថាការសោកស្តាយ និងការឆ្លុះបញ្ចាំងត្រឡប់មកវិញពីខ្លួនឯងទាំងនោះក៏ជា "ផ្លែផ្កា" ដ៏ប្រាកដប្រជាដែលនឹងជួយយើងសម្រាប់ប្រឈមមុខនឹងរដូវរងាដែរ។

ផ្លែទន្លាប់ និងផ្លែក្រចាប់ដែលគេប្រមូលផលនៅរដូវស្លឹកឈើជ្រុះ នឹងមិនមានប្រយោជន៍សម្រាប់យើងទេ ប្រសិនបើយើងមិនចូលចិត្តរសជាតិចត់និងរាងស្រួចរបស់វា ប៉ុន្តែប្រសិនបើយើងទទួលយកពួកវាថាជាការប្រមូលផលដ៏សម្បូរបែប ហើយចំណាយពេលដើម្បីកែច្នៃវា យើងអាចទទួលទានវាបានយ៉ាងឆ្ងាញ់ពិសា។ ដោយវិធីដូចគ្នានេះដែរគេអាចនិយាយបានថា "ការប្រមូលផល" ជាអារម្មណ៍ជូរចត់និងបម្រែវាឱ្យទៅជាអាហារបំប៉នសម្រាប់ព្រលឹងជាថាម ពលដើម្បីប្រឈមនឹងរដូវរងាគឺជាផ្លែផ្កាដ៏អស្ចារ្យដែលអាចទទួលបានតែនៅពេលនោះ។

## រដូវរងាគឺជាពេលវេលាសម្រាប់ការរៀនសូត្រ

កាលពី២៦០០ ឆ្នាំមុន ខុងជឺ ដែលបានទទួលមរណៈភាពនៅអាយុ ៧៤ឆ្នាំ បានពិពណ៌នាអំពីដំណើរខាងសតិវិញ្ញាណផ្ទាល់ខ្លួនរបស់គាត់នៅក្នុងសៀវភៅ "The Analects of Confucius"ថា"នៅអាយុហាសិបខ្ញុំដឹងពីឆន្ទៈដែលទេវតាបញ្ជាមកខ្ញុំ។ នៅអាយុហុកសិបខ្ញុំស្តាប់ពាក្យរបស់អ្នកដទៃដោយបានបទ។ នៅអាយុចិតសិបខ្ញុំធ្វើតាមបំណងប្រាថ្នារបស់បេះដូងខ្ញុំដោយមិនឱ្យហួសព្រំដែននៃគុណធម៌" ។ នៅរដូវស្លឹកឈើជ្រុះនៃជីវិត មនុស្សស្គាល់គោលការណ៍នៃផែនដី និងធម្មជាតិ ហើយនៅពេលដែលមនុស្សស្តាប់អ្នកដទៃនិយាយគេនឹងត្រូវចិត្តនឹងគោលការ ណ៍របស់អ្នកនោះ លុះដល់ពេលដែលចូលទៅដល់ដូវរងានៃជីវិត គេនឹងមានដំណើរជីវិតដែលប្រព្រឹត្តទៅៗតាមចិត្តចង់របស់គេដោយធម្មជាតិ ដោយមិនឃ្លាតចាកពីគន្លងសីលធម៌ និងវិន័យឡើយ។

ខ្ញុំព្រះករុណាអាត្មាភាពសព្វថ្ងៃចូលដល់ពាក់កណ្តាលរដូវរងានៃជីវិតហើយ។ ក្នុងនាមជាមនុស្សម្នាក់ ខ្ញុំព្រះករុណាអាត្មាភាពមិនទាន់បានឈានទៅដល់ភាពចាស់ទុំនៃចិត្តបែបនេះទេ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ប្រសិន បើយើងពិចារណាទៅលើអាយុកាលជាមធ្យមនៅពេលនោះ និងឥឡូវនេះ អាយុ ៧០ ឆ្នាំរបស់ខុងជឺមានប្រហែលនឹងអាយុ ១១០ ឆ្នាំនៃមនុស្សនាបច្ចុប្បន្នកាលនេះ។ ក្នុងនាមជាមនុស្សដែលមានអាយុអាយុ៨០ ឆ្នាំប្លាយ ខ្ញុំព្រះករុណាអាត្មាភាពនៅមានអ្វីជាច្រើនដែលត្រូវរៀនសូត្រហើយមានអ្វីជាច្រើនដែលខ្ញុំព្រះករុណាអាត្មាភាពមិនដឹងមិនយល់ ។ក្នុងន័យនេះ ខ្ញុំព្រះករុណាអាត្មាភាពត្រូវតែរៀនសូត្របន្ថែមឱ្យបានច្រើនទៀត។

សេចក្តីប្រាថ្នានេះគឺជាអ្វីមួយដែលដូចជាសភាវគតិដែលមនុស្សគ្រប់រូបមាន។ លើសពីនេះទៅទៀត ប្រសិនបើយើងមានបំណងចង់រៀនសូត្រ យើងអាចជួបប្រទះនូវអ្វីដែលថ្មីមិនថាយើងចាស់ប៉ុណ្ណានោះទេ ហើយភាពរីករាយ និងរំភើបដែលយើងបានជួបប្រទះនោះនឹងផ្តល់ថាមពលដល់យើងក្នុងការរស់នៅ ក៏ដូចជាភាពរីករាយក្នុងការឆ្លងកាត់រដូវរងានៃជីវិតដែរ។( Kitamura Seibo) ដែលគេស្គាល់តាមរូបសំណាកសន្តិភាពនៅខេត្តណាង៉ាសាគី( Nagasaki)លោកមានអាយុ ១០០ ឆ្នាំ (តាមប្រព័ន្ធគណនាអាយុតាមបែបប្រពៃណីរបស់ជប៉ុន ) នៅក្នុងការសន្ទ នាជាមួយនឹងព្រះស្ថាបនិកកៃសូសាម៉ាដែលនៅពេលនោះលោកមានជន្មាយុ ៧៧វស្សាគាត់បានលាតត្រដាងថាអាថ៌កំបាំងនៃអាយុវែងនិងសុខភាពល្អគឺ "កុំខឹងហើយកុំគិតសាំញ៉ាំច្រើន"។

ព្រះស្ថាបនិកកៃសូសាម៉ាបានឆ្លើយតបថា "បន្ថែមពីលើនេះគឺកុំកុហក" ។ពេលនោះវិស្វករចម្លាក់បានឆ្លើយថា "ប្រសិនបើអ្នកមិនកុហកទេបេះដូងរបស់អ្នកនឹងបានបរិសុទ្ធហើយកាលណាបេះដូងអ្នកបរិសុទ្ធសុខភាពរបស់អ្នកក៏ល្អទៅតាមនោះ" ។នៅពេលដែលសុំឱ្យលោកសរសេរពាក្យមួយឃ្លាដោយជក់លោកបានសរសេរថា "សម្អាតចិត្តនឹងរស់នៅបានយូរ" ដែលបង្ហាញពីអាកប្បកិរិយាធម្មតារបស់លោកជារៀងរាល់ថ្ងៃ។



"ព្យាយាមខំប្រឹងសិក្សាឱ្យស៊ីជម្រៅ មានចិត្តស្មោះត្រង់មិនជំទើតជើងឱ្យឃើញថាខ្លួនគ្រាន់បើ" អាកប្បកិរិយានេះប្រាកដជាៗគំរូដល់អនុជនជំនាន់ក្រោយ។ខ្ញុំព្រះករុណាអាត្មាភាពនឹងត្រឡប់មកប្រធានបទការសិក្សាស៊ីជម្រៅក្នុងអត្ថបទមួយទៀតនៅខែក្រោយ។

From Kosei, September 2025




# A Global Buddhist Movement




**Information about local Dharma centers**

**facebook**

**X**

We welcome comments on our newsletter Living the Lotus: [living.the.lotus.rk-international@kosei-kai.or.jp](mailto:living.the.lotus.rk-international@kosei-kai.or.jp)